35/11

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ៖ ៩២៥

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧

**សាលដីកា**

លេខ៖ ១៤៩ ក្រV «វ»

ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ ៖ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២២ ដោយមានសមាសភាពដូចតទៅ ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

[redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩២៥ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ លើ ៖

១-ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះគ្មានលេខ ផ្លូវជាតិ [redacted] ណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន០១ នាក់ ឪពុកឈ្មោះ [redacted] «រ» ម្តាយឈ្មោះ [redacted] «រ» ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

-មេធាវី [redacted] សុវណ្ណ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៩៨ "ច".ជ.ឃ.ជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

២-ជនជាប់ចោទឈ្មោះ [redacted] លាង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិវៀតណាម ទីកន្លែងកំណើតនៅប្រទេសវៀតណាម ទីលំនៅបច្ចុប្បន្នជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ [redacted] ធីហ្វាងអៀន "រ" មានកូន០២នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" បច្ចុប្បន្នជាទណ្ឌិតដែលជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ព្រៃស) រយៈពេល៣០ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០៣ "ច".ជឃជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។





Scanned with CamScanner

135/1C

៣-ជនជាប់ចោទឈ្មោះ[redacted]សៅ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិគោកកោ ឃុំគោកកោ ស្រុកជង្កោ ខេត្តកណ្ដាល បច្ចុប្បន្នជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ[redacted]រ" មានកូន ៤នាក់ ឪពុកឈ្មោ[redacted] "រ" ម្ដាយឈ្មោះ[redacted] "ស" **(ប្ដឹងឧទ្ធរណ៍)**

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៩៩ "ច".ដយដ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-មេធាវី[redacted]សុវណ្ណ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

៤-ជនជាប់ចោទឈ្មោ[redacted]ង្ហា ហៅ សឹង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅកម្ពុជាក្រោម ទីលំនៅបច្ចុប្បន្នជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ ព្រាប សៅ "រ" លែងលះ មានកូន២នាក់ ឪពុកឈ្មោះ[redacted]"ស" ម្ដាយឈ្មោ[redacted] "រ" បច្ចុប្បន្នជាទណ្ឌិតជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ព្រៃស)។ **(ប្ដឹងឧទ្ធរណ៍)**

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០០ "ច" ដ.យ.ដ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-មេធា[redacted]សុវណ្ណ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

៥-ឈ្មោះ[redacted] SAMUEL ភេទប្រុស អាយុ៣៦ឆ្នាំជនជាតិNIGERIAN កើតនៅប្រទេស NIGERIA ទីលំនៅបច្ចុប្បន្ននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ TUI មានកូន០១នាក់ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ PEACE "ស" បច្ចុប្បន្នកំពុងជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ **(ប្ដឹងឧទ្ធរណ៍)**

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០២ "ច" ដ.យ.ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-មេធាវី[redacted] សេដ្ឋសម្ផស្ស ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-លោក [redacted] តារា ជាអ្នកបកប្រែភាសា។

៦-ឈ្មោះ[redacted] BENTO ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិ BISSAU កើតនៅប្រទេស GUINEA ឪពុកឈ្មោះ A[redacted]TO "ស" ម្ដាយឈ្មោ[redacted]BENTO "ស" បច្ចុប្បន្នកំពុងជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។**(ប្ដឹងឧទ្ធរណ៍)**

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០១ "ច".ដយដ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-មេធាវី[redacted]ស៊ីដាណា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

-លោក[redacted] តារា ជាអ្នកបកប្រែភាសា។

៧-ជនជាប់ចោទឈ្មោ[redacted]ថារី ហៅ [redacted]ារី ភេទប្រុស កើតឆ្នាំ១៩៨៣ ជាតិខ្មែរ មុខរបរនៅផ្ទះ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៦២០៥៣៨ ទីកន្លែងកំណើតនៅភូមិត្រែង ឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នផ្ទះលេ[redacted]សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]"ស" ម្ដាយ ឈ្មោះ [redacted] ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ម១ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុគ្រឿងញៀន។ (ក្រៅឃុំ)

<u>ជាប់ចោទពីបទ</u> ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តនៃក្រុមហ៊ុនអង្គរអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានី

ភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៨ , ២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

<u>អង្គហេតុមានដូចតទៅ ៖</u>

កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១៣និង៣០នាទី មន្ត្រីនគរបាលការិយាល័យអន្តរាគមន៍ នៃមន្ទីរប្រឆាំងគ្រឿងញៀនបានឃាត់ខ្លួនជនជាប់ចោទម្នាក់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ភេទប្រុស ឆែកឆេរលើខ្លួនឃើញមានក្រាមពណ៌សថ្លាសង្ស័យថាជាសារធាតុញៀនចំនួន០២កញ្ចប់ ហើយបានបន្តទៅឆែកឆេរបន្ទប់លេខ ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ រកឃើញក្រាមពណ៌សថ្លា១៩កញ្ចប់ ថ្នាំគ្រាប់ពណ៌ផ្កាឈូក០៨កញ្ចប់ និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនមួយគ្រឿង។ ក្រោយពីស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា សមត្ថកិច្ចបានបន្តទៅនាំខ្លួនជនជាប់ចោទម្នាក់ និងទណ្ឌិតពីនោក់ពីពន្ធនាគារព្រៃស មកសាកសួរយកចម្លើយមានឈ្មោ[redacted] វង្ឍា ហៅ សឹង ភេទប្រុស អាយុ៣៩ឆ្នាំ ,ឈ្មោះ[redacted]សៅ ភេទប្រុស អាយុ ៤៥ឆ្នាំ និងឈ្មោះ[redacted] លាង ភេទប្រុស អាយុ៣៧ឆ្នាំ។ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឈ្មោះ ធូរ៉ា ហៅ ត្រា ឈ្មោះ[redacted]វង្ឍា ហៅ សឹង្គ និង ឈ្មោះ [redacted] សៅ, បានសហការជាមួយសមត្ថកិច្ចដោយឲ្យជនជាប់ចោទឈ្មោះ ធូរ៉ា ហៅត្រា នាំសមត្ថកិច្ចទៅយកគ្រឿងញៀនប្រភេទ WY ចំនួន ១៧សុង (ប្រហែល ១០ម៉ឺនគ្រាប់) ដែលពួកគេបានទទួលបញ្ជាពីមេជួញដូរគ្រឿងញៀនក្នុងពន្ធនាគារទុកប្រគល់ឲ្យម៉ូយទិញគ្រឿងញៀនយកទៅលក់បន្ត។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ធូរ៉ា , ឈ្មោះ[redacted] វង្ឍា ,ឈ្មោះ [redacted]សៅ គឺទទួលបញ្ជាពីក្នុងពន្ធនាគារ ដោយមានឈ្មោះ[redacted]BENTO ហៅ បាឡា ភេទប្រុស, ឈ្មោះ[redacted] SAMUEL ហៅ បាបា ភេទប្រុស ជនជាតិស្បែកខ្មៅ និងឈ្មោះ [redacted] លាង ជាមេក្លោងគ្រឿងញៀនបានធ្វើការបញ្ជាឲ្យឈ្មោះ[redacted] ធូរ៉ា ដែលនៅខាងក្រៅឲ្យធ្វើសកម្មភាពជួញដូរគ្រឿងញៀន និងតាមចម្លើយសារភាពរបស់ឈ្មោះ [redacted]វង្ឍា បានបញ្ជាក់ថា កន្លងមកឈ្មោះ មេជួញដូរគ្រឿងញៀននៅមុំពេទ្យលោកសង្ឃបានទទួលទិញគ្រឿងញៀនពីឈ្មោះ លាង យកទៅលក់បន្ត ហើយឈ្មោះ លាង បានប្រាប់ឲ្យឈ្មោ[redacted] វង្ឍា បញ្ជាមកឈ្មោះ [redacted]ធូរ៉ា ទំនាក់ទំនងឈ្មោះ វី ឡើងវិញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៨៤ (ព) «ក្រ៨» ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទ ៖

ក.ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ

ខ.ឈ្មោះ[redacted]លាង ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិវៀតណាម

គ. ឈ្មោះ [redacted] សៅ ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ

ឃ.ឈ្មោះ [redacted]វង្ឍា ហៅ សឹង ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ។

ង.ឈ្មោះ [redacted]SAMUEL ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិ NIGERIAN

135/8

ច.ឈ្មា[redacted] BENTO ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិ BISSAU

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ អស់មួយជីវិត ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ , ទី២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឲ្យរួចខ្លួនពីបទចោទប្រកាន់លើ ឈ្មោះ [redacted]រី ហៅ[redacted]រី ហៅ វី ភេទប្រុស កើតឆ្នាំ ១៩៨៣ ជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គស៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨, ២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-រឹបអូសវត្ថុចាប់យកដែលមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៨៣ អយជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមាន ៖

ក.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ថ្នាំគ្រាប់ពណ៌ផ្កាឈូកមានទម្ងន់ថ្នាំសុទ្ធ ៣,០៤ ក្រាម ច្រកចូលក្នុងកូនថង់តូចៗចំនួន ៣។

ខ.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ក្រាមពណ៌សថ្លាមានទម្ងន់ជាក្រាមសុទ្ធ ៨,០២ ក្រាម ច្រកចូលក្នុងកូនថង់តូចៗចំនួន៣។

គ.ទូរស័ព្ទដៃពីរគ្រឿងម៉ាកណូគាអិនចុចពិលពណ៌ខ្មៅលាយខៀវមួយគ្រឿង និងម៉ាកសាំសុងពណ៌សមួយគ្រឿង។

ឃ.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនមួយគ្រឿង។

ង.ថង់ពណ៌ស មានដាក់កូនសៀវភៅពណ៌ខ្មៅតូច០១ ,កាសទូរស័ព្ទអាយហ្វូន ចំនួន០១, ឡាមសម្រាប់កាត់មួយប្រអប់ និងកូនម៉ូឌឹមតូចពណ៌ខ្មៅចំនួន០១ និងឯកសារ ផ្សេងៗ។

ច.ថង់ពណ៌ស មានកូនថង់តូចសម្រាប់ដាក់គ្រឿងញៀន។

ឆ.ប្រអប់ពណ៌ប្រផេះមានអក្សរដាក់ថា Pedro ចំនួន ១។

ជ.កេសដែកដាក់គ្រឿងញៀនពណ៌ផ្ទៃមេឃបិទជិត ដោយគណៈកម្មាការត្រួតពិនិត្យវត្ថុតាងចំនួន ០១។

៤-បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ២៥៩ ដចន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] ធូរ៉ា ហៅ ត្រា, ឈ្មោះ[redacted]ដ្ឋា ហៅ សឹង, ឈ្មោះ[redacted] សៅ, ឈ្មោះ [redacted] AMAECHI

SAMUEL ឈ្មោះ [redacted] BENTO, ឈ្មោះ [redacted] លាង មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ លោក [redacted] ឡាយយី , លោក [redacted] ណ្ណារ៉េត, លោក [redacted] ទីលីន, លោក [redacted] មុន្នីជាតិ, លោក [redacted] គ្រុយ លោកស្រី [redacted] សុខា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ថាវី ហៅ [redacted] ភ៉ាវី ហៅ វី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០១៧។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៦៧៣ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] BENTO, លេខ ៦៧៥ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] SAMUEL, លេខ ៦៩៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោ [redacted] សៅ , លេខ ៦៩៥ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោ [redacted] ធូរ៉ា និងលេខ ៦៩៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៨៤ (ព) «ក្រ៨» ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។

<u>នាពេលសវនាការ</u>

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

១-ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា (វត្តមាន)

២-ជនជាប់ចោទឈ្មោះ [redacted] សៅ (វត្តមាន)

៣-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា (វត្តមាន)

៤-ជនជាប់ចោទឈ្មោះ [redacted] BENTO (វត្តមាន)

៥-ជនជាប់ចោទឈ្មោះ [redacted] I SAMUEL(វត្តមាន)

-មេធា [redacted] សុវណ្ណ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-មេធា [redacted] ស៊ីដាណា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-មេធា [redacted] សេដ្ឋសម្ផស្ស ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-លោក [redacted] តារា ជាអ្នកបកប្រែភាសា (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា បានឆ្លើយនាពេលសវនាការថា ៖ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ដំបូងដកហូតបានតែ០២កញ្ចប់ទេ ក្រោយមកសមត្ថកិច្ចបន្តឆែកឆេរហូតដល់ចំណុចផ្ទះលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដកហូតបានថ្នាំញៀន ១៩កញ្ចប់ទៀត ។ ថ្នាំញៀនទាំងនេះបានមកតាមរយៈឈ្មោះ [redacted] លាង ដែលឈ្មោះ ស៊ុនរដ្ឋា និងឈ្មោះ [redacted] សៅ ជាអ្នកណែនាំឲ្យខ្លួនស្គាល់។ ឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] សៅ ជាអ្នកណែនាំខ្លួន

135/6

ឲ្យជួបឈ្មោះ[redacted] លាង ដោយឲ្យខ្លួនជួយដឹកថ្នាំញៀនឲ្យឈ្មោះ [redacted]លាង ដើម្បីបានទទួលប្រាក់ឈ្នួលខ្លះ ហើយមូលហេតុដែលខ្លួនប្តឹងឧទ្ធរណ៍មកនេះ គឺដោយសារខ្លួនបានដឹងកំហុសហើយ និងសុំឲ្យតុលាការធ្វើការបន្ធូរបន្ថយខ្លះ ព្រោះទោសដាក់ពន្ធនាគារមួយជីវិតគឺមានលក្ខណៈធ្ងន់ធ្ងរពេក ។

-ជនជាប់ចោទឈ្មោះ[redacted] វង្ហា បានឆ្លើយនាពេលសវនាការថា ៖ ខ្លួនស្គាល់ឈ្មោះ[redacted]ធូ៉ា ព្រោះនៅស្រុកជាអ្នករស់នៅស្រុកភូមិជាមួយគ្នា។ ខ្លួនជាអ្នកទំនាក់ទំនងយកលេខទូរស័ព្ទរបស់ឈ្មោះ ធូ៉ា ទៅឲ្យឈ្មោះ [redacted]លាង ដើម្បីឲ្យឈ្មោះ[redacted]ធូ៉ា យកគ្រឿងញៀនលក់ឲ្យឈ្មោះ [redacted] លាង។ ខ្លួនអត់ដឹងថាថ្នាំញៀននៅបន្ទប់របស់ឈ្មោះ [redacted] ធូ៉ា ហៅ ត មានប៉ុន្មានគីឡូក្រាមទេ ខ្លួនគ្រាន់តែដឹងថាឈ្មោះ[redacted] លាង ជាអ្នកបញ្ជាឲ្យឈ្មោះ [redacted] ធូ៉ា ហៅ ត្រា យកថ្នាំញៀនទៅទុកនៅបន្ទប់គាត់។ ឈ្មោះ[redacted] លាង ជាប់ឃុំក្នុងពន្ធនាគារ ជាអ្នកបញ្ជាឲ្យយកទៅអោយម៉ូយ។ ចំពោះជនបរទេសពីរនាក់នោះគឺត្រូវបានឃុំនៅក្នុងបន្ទប់ជាមួយ [redacted] លាង ហើយខ្លួនធ្លាប់ឃើញអ្នកទាំងនោះនិយាយគ្នាជាភាសាអង់គ្លេស ទើបខ្លួនគិតថាជនបរទេសនោះជាមេខ្លោងដែរ។ ប្តឹងឧទ្ធរណ៍មកនេះដើម្បីសុំស្តានសម្រាលទោស ព្រោះការដាក់ពន្ធនាគារមួយជីវិតគឺមានលក្ខណៈធ្ងន់ធ្ងរពេក។

-ជនជាប់ចោទឈ្មោះ[redacted]សៅ បានឆ្លើយនាពេលសវនាការថា ៖ ខ្លួនជាអ្នកយកលេខ[redacted]ធូ៉ា ពី [redacted] វង្ហា យកទៅឲ្យ [redacted] លាង តែខ្លួនមិនដឹងថាគេយកលេខទៅធ្វើអីនោះទេ។ ហើយក៏មិនដែលទិញគ្រឿងញៀនពី[redacted] លាង ដែរ។ ខ្លួន និង[redacted] លាង រួមទាំងជនបរទេស២នាក់នោះ គឺឃុំនៅបន្ទប់ជាមួយគ្នា ហើយខ្លួនធ្លាប់ឃើញឈ្មោះ [redacted] លាង និយាយជាមួយជនបរទេស២នាក់នោះ តែមិនដឹងនិយាយពីអ្វីទេ។ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។

-ជនជាប់ចោទឈ្មោះ [redacted] SAMEUL បានឆ្លើយនាពេលសវនាការថា ៖ ខ្លួនត្រូវតុលាការផ្តន្ទាទោសចំនួន២៥ឆ្នាំ ចំពោះបទល្មើសមុន។ តែចំពោះករណីនេះ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ កន្លងមកខ្លួនក៏មិនដែលស្គាល់ឈ្មោះ[redacted] វង្ហា ,ឈ្មោះ[redacted] ធូ៉ា , ឈ្មោះ[redacted] សៅ និងឈ្មោះ [redacted] លាង នោះទេ ពេលកើតរឿងនេះហើយទេ ទើបខ្លួនស្គាល់មុខ។ ចំពោះឈ្មោះ[redacted] លាង គឺខ្លួនមិនដែលនិយាយជាមួយទេ គ្រាន់តែធ្លាប់ដេកក្បែរគ្នា។ ប៉ុន្មានថ្ងៃមុនកើតហេតុគឺឈ្មោះ [redacted] BENTO ឈ្លោះគ្នាជាមួយឈ្មោះ[redacted]វង្ហា ខ្លួនបានចូលទៅឃាត់ ។

-ជនជាប់ចោទឈ្មោះ[redacted] BENTO បានឆ្លើយនាពេលសវនាការថា ៖ ខ្លួនត្រូវតុលាការផ្តន្ទាទោសចំនួន២៧ឆ្នាំ និងស្នាក់នៅបន្ទប់លេខ C18 ។ ខ្លួនសូមបដិសេធថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ចំពោះជនជាតិខ្មែរទាំងអស់នេះ ខ្លួនមិនដែលស្គាល់ទេ ទើបតែស្គាល់នៅពេលកើតហេតុនេះឯង។ ហើយឈ្មោះ [redacted]វង្ហា គឺគេធ្លាប់ដើរជាន់ជើងខ្លួន ទើបនាំឲ្យមានទំនាស់តែមិនបានវាយប្រតាយប្រតប់អីទេ ព្រោះត្រូវមន្ត្រីពន្ធនាគារបំបែកទាន់។ ចំពោះឈ្មោះ [redacted]លាង គឺខ្លួនមិនដែលស្គាល់ទេ។

-តំណាងមហាអយ្យការយល់ឃើញថា ក្រោយពីបានធ្វើការពិភាក្សាដេញដោល និងបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងប្រាំនាក់ក្នុងពេលសវនាការ រួចហើយមក តំណាងមហាអយ្យការពិនិត្យឃើញថាជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ

ចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គរស៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨, ២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ នៅពេលសវនាការ ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា បានឆ្លើយសារភាពកំហុស និងទទួលស្គាល់ថាខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហើយប្តឹងឧទ្ធរណ៍មកនេះគឺដើម្បីសុំស្ថានសម្រាលទោស ហេតុនេះសូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាដោយផ្អែកថាឈ្មោះ [redacted] ធូរ៉ា ក៏បានសហការជាមួយសមត្ថកិច្ចរហូតចាប់បានខ្លួនមេខ្លោង។ ជនជាប់ចោទឈ្មោះ [redacted] វង្សា វិញ បើពិនិត្យមើលលើចម្លើយនៅសាលាដំបូងបានឆ្លើយដាក់បន្ទុកជនបរទេស តែនាសវនាការពេលនេះបែរឆ្លើយថាខ្លួនគ្រាន់តែប៉ាន់ស្មានប៉ុណ្ណោះដែលជាចម្លើយដោះបន្ទុកឲ្យជនបរទេសខុសពីចម្លើយនៅសាលាដំបូង សូមក្រុមប្រឹក្សាជំនុំជម្រះពិនិត្យត្រង់ចំណុចនេះ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] សៅ , ឈ្មោះ [redacted]AMEUL និងឈ្មោះ [redacted]ENTO វិញ បានឆ្លើយបដិសេធរហូតថាខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ផ្ទុយទៅចម្លើយដាក់បន្ទុករបស់ជនជាប់ចោទឈ្មោះ [redacted] វង្សា ។ ហេតុនេះ ស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេច ដោយផ្អែកលើចំណុចនិងភស្តុតាងដូចបានលើកឡើងខាងលើ។

-មេធាវី [redacted] សុវណ្ណ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វង្សា ,ឈ្មោះ [redacted] ធូរ៉ា និងឈ្មោះ [redacted] សៅ ៖ ខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សូមធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅ។ ក្រោយពីបានស្តាប់នូវការសួរដេញដោលក្នុងពេលសវនាការ ឃើញថាកូនក្តីខ្លួនឈ្មោះ [redacted] ធូរ៉ា និងឈ្មោះ [redacted] វង្សា បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាល ថែមទាំងបានជួយសហការជាមួយសមត្ថកិច្ចទៀតផង ហេតុនេះសំណូមពរក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តល់នូវស្ថានសម្រាលទោស តាមបញ្ញត្តិមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដោយឡែកចំពោះឈ្មោះ [redacted] សៅ បានឆ្លើយបដិសេធរហូតមកថាខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហេតុនេះសូមឲ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាសម្រេចឲ្យរួចផុតពីបទចោទ។

-មេធាវី [redacted] ស៊ីដាណា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] BENTO ៖ សូមធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ។ កូនក្តីខ្លួន បានឆ្លើយបដិសេធថាពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តាំងពីនៅដំណាក់កាលសាលាដំបូងរហូតមកដល់បច្ចុប្បន្ន ហើយក៏គ្មានភស្តុតាងដាក់បន្ទុកមកលើកូនក្តីខ្លួនដែរ។ ហេតុនេះ សំណូមពរឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ ដោយហេតុផលថាវិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ។

-មេធាវី [redacted] សេដ្ឋសម្ផស្ស ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោ[redacted] SAMEUL ៖ សូមធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ។ ចំពោះអង្គហេតុនេះ កូនក្តីខ្លួនគឺពុំមានជាប់ពាក់ព័ន្ធទេ ហើយក៏ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់មកលើកូនក្តីខ្លួននោះដែរ ក្រៅពីចម្លើយដាក់បន្ទុករបស់

135/4

ជនជាប់ចោទ [redacted] វង្ហា។ ហេតុនេះ សំណូមពរឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចបដិសេធសាលក្រមសាលាដំបូង និងឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

## <u>សំណូមពរចុងក្រោយរបស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ៖ សូមតុលាការមេត្តាបន្ធូរបន្ថយទោសមកលើរូបខ្លួនផង ដើម្បីឲ្យខ្លួនមានសេរីភាពវិញ ព្រោះខ្លួនបានដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ង្ហា ៖ សូមតុលាការមេត្តាបន្ធូរបន្ថយទោសមកលើរូបខ្លួនផង ដើម្បីឲ្យខ្លួនមានឱកាសអាចកែខ្លួនឡើងវិញ ព្រោះខ្លួនបានដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សៅ ៖ សូមតុលាការមេត្តាបន្ធូរបន្ថយទោសមកលើរូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] SAMUEL៖ សូមតុលាការជួយរក ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-ជនជាប់ចោទឈ្មោះ [redacted] BENTO ៖ សូមតុលាការមេត្តាលើកលែងការចោទប្រកាន់លើរូបខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ។
-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ។
-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។
-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>សាលាឧទ្ធរណ៍យល់ឃើញថា</u>

១/. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ OKEKE AN[redacted] SAMUEL ,ឈ្មោះ [redacted] BENTO និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ,ឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] ង្ហា ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៨៤ (ព) «ក្រ៨» ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះ។

២/. តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល នាពេលសវនាការឃើញថា : កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦ មន្ត្រីនគរបាលការិយាល័យអន្តរាគមន៍ នៃមន្ទីរប្រឆាំងគ្រឿងញៀនបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា រួចបន្តឆែកឆេរទៅដល់ចំណុចបន្ទប់លេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌ

ឬស្សីកែវ រាជធានីភ្នំពេញ រកឃើញសារធាតុញៀនសរុបចំនួន២១កញ្ចប់ ក្រោយធ្វើកោសលវិច័យឃើញ ថាជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន មានបរិមាណធាតុសុទ្ធទម្ងន់សរុបចំនួន $\frac{៣.០១២,៩ x ៨១,៩៩}{១០០}$ = ២.៤៧០,២៧ ក្រាម និងថ្នាំគ្រាប់ពណ៌ផ្កាឈូក ក្រោយកោសលវិច័យឃើញថាជាសារធាតុញៀនប្រភេទ មេតំហ្វេតាមីន មានបរិមាណធាតុសុទ្ធទម្ងន់សរុបចំនួន $\frac{១០.៤១០,៧ x ១៦,៦០}{១០០}$ = ១.៧២៨,១៧ ក្រាម ប្រាកដមែន និងបន្តឃាត់ខ្លួនបានបក្សពួកមានឈ្មោះ[redacted] វង្ហា និងឈ្មោះ[redacted] សៅ ។ ជនជាប់ចោទទាំងបីនាក់ បានឆ្លើយសារភាពនៅចំពោះមុខសមត្ថកិច្ចថា ពួកគេបានទទួលបញ្ជាពីមេខ្លោងជួញដូរគ្រឿងញៀនក្នុងពន្ធនាគារ ក្នុងនោះមានឈ្មោះ [redacted] BENTO ,ឈ្មោះ [redacted] SAMEUL និងឈ្មោះ[redacted] លាង ជាអ្នកបញ្ជាឲ្យចែកចាយថ្នាំញៀនទាំងនេះយកទៅឲ្យម៉ូយលក់បន្ត។ នេះជាទម្រង់មួយនៃអំពើមានធាតុផ្សំបទល្មើស និងភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចមានក្នុងខ្លឹមសារផ្នែកសំអាងហេតុនៃសាលក្រមរបស់សាលាដំបូងបញ្ជាក់ស្រាប់ ហើយក្រុមប្រឹក្សាជំនុំជម្រះឯកភាពទៅនឹងសំអាងហេតុទាំងនេះ ដោយមិនចាំបាច់លើយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

៣/.តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ជនជាប់ចោទឈ្មោះ[redacted] បានសហការជាមួយសមត្ថកិច្ចរហូតចាប់បានមេខ្លោង។ ជនជាប់ចោទឈ្មោះ[redacted] វង្ហា វិញ បើពិនិត្យមើលលើចម្លើយនៅសាលាដំបូងបានឆ្លើយដាក់បន្ទុកជនបរទេស តែនាសវនាការពេលនេះបែរឆ្លើយថាខ្លួនគ្រាន់តែប៉ាន់ស្មានប៉ុណ្ណោះដែលជាចម្លើយដោះបន្ទុកឲ្យជនបរទេសខុសពីចម្លើយនៅសាលាដំបូង។ ជនជាប់ចោទឈ្មោះ[redacted] សៅ , ឈ្មោះ[redacted] SAMEUL និងឈ្មោះ[redacted] BENTO វិញ បានឆ្លើយបដិសេធរហូតថាខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ផ្ទុយទៅចម្លើយដាក់បន្ទុករបស់ជនជាប់ចោទឈ្មោះ[redacted] វង្ហា ។ ហេតុនេះ ស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចតាមច្បាប់ ដោយផ្អែកលើចំណុចនិងភស្តុតាងដូចបានលើកឡើងខាងលើ។

ឃើញថាសេចក្តីសន្និដ្ឋាននេះ មានលក្ខណៈត្រឹមត្រូវ គប្បីពិចារណា និងសម្រេច។

៤/. ការដែលជនជាប់ចោទឈ្មោះ[redacted] វង្ហា ,ឈ្មោះ[redacted] ធូរ៉ា និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទស្នើសុំឲ្យតុលាការសម្រេចបន្ធូរបន្ថយទោស ឃើញថាពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថាវត្ថុតាងគ្រឿងញៀនជាប្រភេទមេតំហ្វេតាមីន ត្រូវបានសមត្ថកិច្ចធ្វើការដកហូតមានបរិមាណសុទ្ធសរុបដល់ ៤.១៨៨,៤៤ ក្រាម ។ ប៉ុន្តែតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានកំណត់ថា «គ្រឿងញៀនជាប្រភេទមេតំហ្វេតាមីន ដែលមានបរិមាណសុទ្ធចាប់ពី ២៤០(ពីររយសែសិប)ក្រាម

ឡើងទៅ ត្រូវផ្តន្ទាទោសពី ២០(ម្ភៃ) ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំ ឬអស់មួយជីវិត និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន)រៀល ទៅ ១០០.០០០.០០០ (មួយរយលាន)រៀល » ប៉ុន្តែសាលាដំបូងមិនបានធ្វើការប្រកាសទោសពិន័យទៅលើជនជាប់ចោទនោះទេ។ ដូច្នេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ មិនពិចារណាទៅលើការស្នើសុំនេះទេ ។

៥/. ការដែលជនជាប់ចោទឈ្មោះ [redacted] សៅ , ឈ្មោះ [redacted] BENTO , ឈ្មោះ OKEKE [redacted] SAMUEL និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទស្នើសុំឲ្យតុលាការសម្រេចឲ្យជនជាប់ចោទ រួចផុតពីបទចោទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយអះអាងថាជនជាប់ចោទមិនបានប្រព្រឹត្តដូចការចោទប្រកាន់ នោះឃើញថា ពុំមានលក្ខណៈត្រឹមត្រូវឡើយដោយហេតុថា នេះគឺគ្រាន់តែជាចម្លើយដោះសារយករួចខ្លួនដោយគ្មានមូលដ្ឋានក៏ដូចជាភស្តុតាងបញ្ជាក់នោះឡើយ។ ផ្ទុយទៅវិញ បើពិនិត្យទៅលើរបាយការណ៍លេខ ០៥៣ /១៦ ក.ប.គ.៣ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យប្រឆាំងគ្រឿងញៀនបានបញ្ជាក់យ៉ាងច្បាស់ថា « ក្រោយពីបានធ្វើការស្រាវជ្រាវស៊ើបអង្កេតអស់រយៈពេលជាច្រើនខែ ជាលទ្ធផលឃើញថា ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា , ឈ្មោះ [redacted] លាង , ឈ្មោះ [redacted] វង្សា ,ឈ្មោះ [redacted] សៅ , ឈ្មោះ [redacted] BENTO និងឈ្មោះ OKEKE [redacted] AMUEL ពិតជាបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយក្រុមនេះបានចងក្រងជាអង្គការចាត់តាំងជួញដូរគ្រឿងញៀនចេញពីក្នុងពន្ធនាគារព្រៃស ធ្វើការលក់ចែកចាយគ្រឿងញៀនក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ » ហើយចំណុចនេះ គឺមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោ[redacted] ធូរ៉ា និងឈ្មោះ [redacted] វង្សា ដែរ។ ហេតុនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ មិនពិចារណាលើការស្នើសុំនេះទេ ។

៦/. សាលក្រមព្រហ្មទណ្ឌលេខ ៤៨៤ (៣) «ក្រ៨» ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមកមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការដដែល ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១/. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ OKEKE [redacted] AMUEL ,ឈ្មោ[redacted] BENTO និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ,ឈ្មោ[redacted] សៅ និងឈ្មោះ [redacted] វង្សា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២/. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៨៤ (ព) «ក្រ៨» ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣/. បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ។

-ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | [redacted] , [redacted] | [redacted] |

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
នៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២
ក្រឡាបញ្ជី

[redacted]